# សៀវភៅកម្រងព័ត៌មានអប់រំ

# ផ្នែកខេមរភាសា



សាលា អ៊ិនធើណេសិនណាល ស្គូល អហ្វ សៀមរាប

ISSR

# មាតិកា


1. ចំណាប់អារម្មណ៍របស់លោកស្រីអគ្គនាយិកាសាលា សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤
2. សារតារបស់សាលា អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប ផ្នែកខេមរភាសា
3. គោលដៅអប់រំជាតិ
4. ចក្ខុវិស័យ និងបេសកកម្មអប់រំ
5. គុណវឌ្ឍិគ្រូបង្រៀនផ្នែកខេមរភាសា
6. ការបង្រៀន និងរៀនផ្នែកខេមរភាសា
7. ការចូលរួមគាំទ្រ ពីអាណាព្យាបាល សហគមន៍ និងដៃគូ
8. ការលើកទឹកចិត្ត
9. សុខភាព សុវត្ថិភាព និងសន្តិសុខ
10. សម្លៀកបំពាក់ និងឯកសណ្ឋានសិស្សានុសិស្ស
11. សកម្មភាពពិសេស និងសកម្មភាពក្រៅថ្នាក់សិក្សា
12. សកម្មភាពមនុស្សធម៌ក្នុងសង្គម
13. វប្បធម៌របស់សាលាអន្តរជាតិ ISSR
14. អនុសាសន៍
15. សន្និដ្ឋាន

# ចំណាប់អារម្មណ៍របស់លោកស្រីអគ្គនាយិកាសាលា សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤



សូមជម្រាបសួរ និងសូមស្វាគមន៍លោក លោកស្រី ដែលជាមាតា បិតា ឬអ្នកអាណាព្យាបាលសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ បុគ្គលិក ព្រមទាំងប្អូនៗសិស្សានុសិស្សទាំងអស់ជាទីស្រលាញ់ ។

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយណាស់ដែលបានឃើញកូនៗសិស្សានុសិស្ស និងលោក លោកស្រីមានវត្តមាននៅក្នុងបរិវេណសាលាអ៊ិនធើណេសិនណលស្កូលអហ្វសៀមរាបដែលជាថ្នាលបណ្តុះបណ្តាលកម្រិតអន្តរជាតិប្រកបដោយគុណភាព ។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ នាងខ្ញុំសូមអរគុណដល់លោក លោកស្រីជាមាតា បិតា ឬអ្នកអាណាព្យាបាលសិស្សដែលតែងតែជឿទុកចិត្តគាំទ្រ និងសហការជាមួយសាលាISSR និងសូមអរគុណដល់លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ និងបុគ្គលិកទាំងអស់ដែលបានខិតខំប្រឹងប្រែងដើម្បីធានាសុវត្ថិភាព និងគុណភាពនៃការអប់រំប្រកបដោយគុណភាពដល់កូនៗសិស្សានុសិស្ស។

បច្ចុប្បន្ននេះសាលាISSR កំពុងបណ្តុះបណ្តាលសិស្សានុសិស្សតាមកម្មវិធីសិក្សាស្តង់ដាអន្តរជាតិ(Cambridge) និងកម្មវិធីសិក្សាថ្នាក់ជាតិ។ក្នុងន័យនេះកូនៗសិស្សានុសិស្សនឹងទទួលបានការអប់រំស្របតាមកម្មវិធីសិក្សាចំណេះទូទៅស្តង់ដាអន្តរជាតិ (Cambridge) ដែលឈានមុខគេមួយរបស់ពិភពលោក មានសាលារៀនជាង១០,០០០សាលា នៅក្នុងជាង១៦០ ប្រទេស។

ក្នុងនេះផងដែរខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្នុងការណែនាំអំពីប្រព័ន្ធគ្រប់គ្រងអប់រំថ្មីដល់លោក លោកស្រីដែលមានឈ្មោះថា "EDUPAGE" ។ ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យលោក លោកស្រីចូលប្រើប្រាស់ និងតាមដានពីវឌ្ឍនភាពរបស់កូនៗ កាលវិភាគសិក្សា ព័ត៌មានពីការសិក្សារបស់កូនៗ កិច្ចការផ្ទះ និងអ្វីៗជាច្រើនទៀត ដោយលោក លោកស្រី អាចចូលទៅប្រើប្រាស់បានតាមរយៈការដូនឡូតApp លើកុំព្យូទ័រ ឬកម្មវិធីទូរស័ព្ទ Edupage ។ Edupage នឹងផ្តល់ភាពងាយស្រួលប្រកបដោយសុវត្ថិភាព ជួយសម្រួលការងារទំនាក់ទំនងរវាងសាលា គ្រួសារ និងសិស្សានុសិស្សរបស់យើង។ កម្មវិធីនេះនឹងដាក់ឱ្យដំណើរការប្រើប្រាស់ចាប់ពីខែសីហា ឆ្នាំ ២០២៣ ខាងមុខនេះ។

ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមជម្រាបជូនលោក លោកស្រី អំពីផែនការអភិវឌ្ឍរបស់វិទ្យាល័យយើង ដែលនឹងពង្រីកទីធ្លាកាន់តែធំជាងមុនទ្វេដង ហើយពួកយើងគ្រោងនឹងសាងសង់បន្ថែមនូវអគារសម្រាប់ពិសោធនវិទ្យាសាស្ត្រ បុគ្គលិក និងកន្លែងទទួលទានអាហារ សាលប្រជុំបំពាក់ដោយម៉ាស៊ីនត្រជាក់ ការិយាល័យរដ្ឋបាល និងចំណតក្រោមដី។ ទីធ្លាអាណាព្យាបាលជូនកូនៗមកសាលារៀន និងមកទទួលពួកគេត្រលប់វិញក៏មានទំហំធំជាងមុនផងដែរ។ គម្រោងខាងលើនេះនឹងផ្តល់លទ្ធភាពឱ្យសាលាអាចបង្កើនចំនួនបន្ទប់សិក្សា សាលសហកីឡានៅក្នុងអគារតែម្តង ចំណែកទីលានកីឡាបាល់ទាត់ក៏ពង្រីកទំហំធំជាងមុនទ្វេដងផងដែរ ។ សម្រាប់សិស្សានុសិស្សដែលមកពីបណ្តាខេត្តផ្សេងៗពួកគេក៏មានឱកាសស្នាក់នៅអន្តេវាសិកដ្ឋានដែលនឹងសាងសង់ក្នុងបរិវេណវិទ្យាល័យស្របតាមបទដ្ឋាន ហើយអន្តេវាសិកដ្ឋាននេះនឹងមានច្រកចេញចូលដាច់ដោយឡែកពីសាលារៀន។

សូមអរគុណចំពោះការគាំទ្ររបស់លោក លោកស្រី ហើយពួកយើងរង់ចាំជួបកូនរបស់អ្នកនៅឆ្នាំសិក្សាបន្ទាប់។

អគ្គនាយិកាសាលាអន្តរជាតិ ISSR

**លោកស្រី ឈុន ផល្លិន**

# សាវតារបស់សាលា អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប ផ្នែកខេមរភាសា

ចាប់ពីឆ្នាំ១៩៩៧ រហូតដល់បច្ចុប្បន្ន ប្រព័ន្ធអប់រំចំណេះទូទៅនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់រយៈពេលនៃការសិក្សាមានចំនួន១២ឆ្នាំក្នុងនោះមានកម្រិតបឋមសិក្សាចំនួន៦ឆ្នាំមធ្យមសិក្សាបឋមភូមិចំនួន៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិចំនួន៣ឆ្នាំ ។

សាលាISSR គឺជាគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន ដែលមានការទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ២២២១ អយក.ប្រក និង២២២២ អយក.ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ អនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលថ្នាក់ចំណេះទូទៅជាភាសាខ្មែរ និងថ្នាក់ចំណេះទូទៅភាសាអង់គ្លេស ចាប់ពីមត្តេយ្យ រហូតដល់ថ្នាក់ទី១២ និង១៣។

សិស្សានុសិស្សដែលរៀនកម្មវិធីចំណេះទូទៅផ្នែកខេមរភាសា នឹងទទួលបានការបណ្តុះបណ្តាលលើកម្មវិធីសិក្សាចំណេះទូទៅភាសាខ្មែរស្របតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងកម្មវិធីសិក្សាភាសាអង់គ្លេស តាមកម្មវិធីរបស់ Cambridge នៃចក្រភពអង់គ្លេស ។ ក្រោយពេលបញ្ចប់ការសិក្សា សិស្សនឹងទទួលបាននូវសញ្ញាបត្រទទួលស្គាល់ពីស្ថាប័ន Cambridge នៃចក្រភពអង់គ្លេស និងពីក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា គឺសញ្ញាបត្រទាំងពីរនេះអាចប្រើប្រាស់បានជាផ្លូវការទាំងក្នុង និងក្រៅប្រទេស។











# គោលដៅអប់រំជាតិ

ការអប់រំនៅប្រទេសកម្ពុជាមានគោលដៅកសាងមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតីសញ្ចេតនា និងរូបកាយ។ គោលដៅនេះ ធានាកសាងនូវពលរដ្ឋថ្លៃថ្នូរ មានចំណេះដឹង បំណិនពិសោធន៍ សីលធម៌ អធ្យាស្រ័យ សហការ សាមគ្គីភាព ឯកភាពជាតិ មនសិការជាតិ ស្រលាញ់យុត្តិធម៌ គោរពច្បាប់សិទ្ធិមនុស្ស យល់ដឹងថែរក្សាការពារបរិស្ថាន ចេះផ្សព្វផ្សាយ និងលើកកម្ពស់តម្លៃវប្បធម៌ អរិយធម៌ជាតិមានម្ចាស់ការ ទំនុកចិត្តលើខ្លួនឯងចេះដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ ចេះច្នៃប្រឌិត ចេះធ្វើពលិកម្ម មានស្មារតីទទួលខុសត្រូវខ្ពស់ មានសមត្ថភាពកសាងសុខមាលភាពគ្រួសារ ហើយអាចចូលរួមយ៉ាងសកម្មក្នុងការងារបង្រួបបង្រួមជាតិ ស្តារ និងអភិវឌ្ឍមាតុភូមិជាទីស្នេហា ដោយផ្អែកលើស្មារតីប្រជាធិបតេយ្យសេរីពហុបក្ស ។ ក្នុងន័យនេះសាលាអន្តរជាតិ ISSR នឹងខិតខំអប់រំ កសាងធនធានសិស្សានុសិស្សឱ្យមានសម្បទាគ្រប់គ្រាន់ និងស្របតាមឧបនិស្ស័យ ដើម្បីធានបាននូវការកសាងធនធានមនុស្សក្នុងជួរបញ្ញវន្តជំនាញៗ និងការគ្រប់គ្រងដឹកនាំក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និងសង្គម សម្រាប់អភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ នាពេលខាងមុខឲ្យបានកាន់តែប្រសើរឡើង ។







# ចក្ខុវិស័យ និងបេសកកម្មអប់រំ

**ចក្ខុវិស័យ** ៖ ផ្តល់សេវាអប់រំចំណេះទូទៅសម្រាប់សិស្សានុសិស្សកម្រិតជាតិ និងអន្តរជាតិ។

**បេសកកម្ម**៖ កសាងធនធានសិស្សានុសិស្សឲ្យក្លាយជាមនុស្សសកលតាមរយៈការផ្តល់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា សម្រាប់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា មានជំនាញច្បាស់លាស់ និងការងារថ្លៃថ្នូរ រស់នៅប្រកបដោយសេចក្តីសុខ មានភាពរីកចម្រើនក្នុងសង្គមគ្រួសារ និងសង្គមជាតិ។

ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ សាលាបានរៀបចំកម្មវិធីសិក្សាស្របតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស បានរៀបចំកាលវិភាគឆ្លាស់គ្នានឹងកម្មវិធីសិក្សាអង់គ្លេសចំណេះទូទៅរបស់ Cambridge នៅក្នុងឆ្នាំសិក្សាតែមួយផងដែរ ដើម្បីឱ្យសិស្សានុសិស្សទទួលបាននូវចំណេះដឹងទូទៅយ៉ាងទូលំទូលាយ ។



# គុណវឌ្ឍិគ្រូបង្រៀនផ្នែកខេមរភាសា

## ធនធានគណៈគ្រប់គ្រង និងគ្រូបង្រៀនផ្នែកមត្តេយ្យ បឋមសិក្សា

ត្រូវបានជ្រើសរើសពីបុគ្គលិកដែលមានក្របខ័ណ្ឌរដ្ឋ មានគរុកោសល្យ មានបទពិសោធន៍បង្រៀន និងគ្រប់គ្រងនៅតាមគ្រឹះស្ថានរដ្ឋចាប់ពី៥ឆ្នាំឡើងទៅ ។





### លោក សាន សុភាព

ជានាយកប្រតិបត្តិផ្នែកខេមរភាសា និងជាគ្រូបង្រៀនកម្រិតឧត្តម មានកម្រិតវប្បធម៌បរិញ្ញាបត្រជាន់ខ្ពស់ មានបទពិសោធន៍ការងារក្នុងការបង្រៀន និងជាអ្នកគ្រប់គ្រងមាន រយៈពេល២១ ឆ្នាំ ក្នុងស្ថាប័នរដ្ឋ និងឯកជន។

### លោក អួង គឹមសឿង

ជាប្រធានផ្នែកគម្រោង នៃផ្នែកខេមរភាសា និងជាគ្រូបង្រៀនកម្រិតឧត្តម កម្រិតវប្បធម៌បរិញ្ញាបត្រជាន់ខ្ពស់ បទពិសោធន៍ការងារ ក្នុងការបង្រៀន និងជាអ្នកគ្រប់គ្រងមានរយៈពេល២១ឆ្នាំ ក្នុងស្ថាប័នរដ្ឋ និងឯកជន ។







### អ្នកគ្រូ ស៊ាន សុផាន់ណា

**ជាគ្រូបង្រៀនថ្នាក់មត្តេយ្យ**
មានបទពិសោធន៍ការងាររយៈពេល៧ឆ្នាំ
កម្រិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ ។

### អ្នកគ្រូ ស៊ុំ សារឿន

**ជាគ្រូបង្រៀនថ្នាក់ទី ១** មានបទពិសោធន៍ការងាររយៈពេល១៧ឆ្នាំ
កម្រិតវប្បធម៌ បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ។

### អ្នកគ្រូ អ៊ុយ ណារិន

**ជាគ្រូបង្រៀនថ្នាក់ទី២** មានបទពិសោធន៍ការងាររយៈពេល១៣ឆ្នាំ
កម្រិតវប្បធម៌ មធ្យមសិក្សាទុតិយភូមិ
បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ។



### អ្នកគ្រូ ជឿន នារីផល

**ជាគ្រូបង្រៀន ថ្នាក់ទី៣**
មានបទពិសោធន៍ការងាររយៈពេល ៧ឆ្នាំ
មានកម្រិតវប្បធម៌បរិញ្ញាបត្រអក្សរ
សាស្ត្រខ្មែរ ។



### អ្នកគ្រូ ជា សាងឹម

**ជាគ្រូបង្រៀន ថ្នាក់ទី៤**
**និងជាគ្រូបង្រៀនកម្រិតឧត្តម** មានបទ
ពិសោធន៍ការងាររយៈពេល ១៣ឆ្នាំ
កម្រិតវប្បធម៌ បរិញ្ញាបត្រជាន់ខ្ពស់
ឯកទេសប្រវត្តិវិទ្យា ។



### លោកគ្រូ អ៊ិន វ៉ាន់ឌីអយ

ជាគ្រូបង្រៀន ថ្នាក់ទី៥ក
មានបទពិសោធន៍ការងាររយៈ
ពេល៦ឆ្នាំ ។ កម្រិតវប្បធម៌ បរិញ្ញាបត្រ
អក្សរសាស្ត្រខ្មែរ



### អ្នកគ្រូ សៀប ចន្ធូ

**ជាគ្រូបង្រៀនថ្នាក់ទី ៦** មានបទ
ពិសោធន៍ការងារ រយៈពេល១៤ឆ្នាំ។
កម្រិតវប្បធម៌បរិញ្ញាបត្រអក្សរសាស្ត្រ
ខ្មែរ ។



### អ្នកគ្រូ ផុន ស្រីនាង

ជាគ្រូបង្រៀនផ្នែករបាំបុរាណខ្មែរ
មានបទពិសោធន៍ការងាររយៈ
ពេល១២ឆ្នាំ។



### លោកគ្រូ ផល សុកេង

ជាគ្រូបង្រៀនផ្នែករបាំបុរាណខ្មែរ
មានបទពិសោធន៍ការងាររយៈ
ពេល ១៣ឆ្នាំ ។



### លោកគ្រូ សន គឹមសួ

លោកគ្រូ សន គឹមសួ  ជាគ្រូបង្រៀន
ផ្នែកតន្ត្រីបុរាណខ្មែរ មានបទ
ពិសោធន៍ការងាររយៈពេល១៤ឆ្នាំ ។



### លោកគ្រូ គឹម វណ្ណា

ជាគ្រូបង្រៀនអប់រំកាយ មានបទ
ពិសោធន៍ រយៈពេលជាង១០ឆ្នាំ។
កម្រិតវប្បធម៌បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែកវិទ្យាសាស្ត្រ កីឡា

# ធនធានគណៈគ្រប់គ្រង និងគ្រូបង្រៀនផ្នែកវិទ្យាល័យ



លោកគ្រូ សាន សុភាព
នាយកប្រតិបត្តិ ផ្នែកខេមរភាសា



លោកគ្រូ អ៊្លង គឹមសឿង
ប្រធានគម្រោងផ្នែកខេមរភាសា



លោកគ្រូ ទូច យ៉ារិន
មុខវិជ្ជា ៖ គណិតវិទ្យា



អ្នកគ្រូ ហាស់ មាលាគន្ធី
មុខវិជ្ជា ៖ ភាសាខ្មែរ



លោកគ្រូ វ៉ាន់ សុវត្ថារា
មុខវិជ្ជា ៖ គណិតវិទ្យា



អ្នកគ្រូ តូវ ងីម
មុខវិជ្ជា ៖ ជីវវិទ្យា



លោកគ្រូ ស៊ិន ពិសិដ្ឋ
មុខវិជ្ជា ៖ គណិតវិទ្យា



អ្នកគ្រូ អ៊ិន បូរ៉ាណែត
មុខវិជ្ជា ៖ ភាសាខ្មែរ & គេហវិទ្យា



លោកគ្រូ ដុង សេងនីន
មុខវិជ្ជា ៖ រូបវិទ្យា



អ្នកគ្រូ ង៉ោ សុន្ទី
មុខវិជ្ជា ៖ ភូមិវិទ្យា



លោកគ្រូ ជា ប៊ុនលេង
មុខវិជ្ជា ៖ គណិតវិទ្យា



អ្នកគ្រូ នេត្រ ចរិយា
មុខវិជ្ជា ៖ សីលធម៌-ពលរដ្ឋ



លោកគ្រូ ភឿន ផាត
មុខវិជ្ជា ៖ រូបវិទ្យា & គីមីវិទ្យា



អ្នកគ្រូ មាស រិទ្ធិនារី
មុខវិជ្ជា ៖ ជីវវិទ្យា & ផែនដីវិទ្យា



លោកគ្រូ សៅ រីណា
មុខវិជ្ជា ៖ គណិតវិទ្យា



អ្នកគ្រូ អាន ចិន្តាស្រីមុច
មុខវិជ្ជា ៖ គីមីវិទ្យា



លោកគ្រូ ជូ សុគន្ធ
មុខវិជ្ជា ៖ ផែនដីបរិស្ថាន& ភូមិវិទ្យា



លោកគ្រូ លាង ងន់ហាក់
មុខវិជ្ជា ៖ ភាសាខ្មែរ



អ្នកគ្រូ ជា សាងឹម
មុខវិជ្ជា ៖ ប្រវត្តិវិទ្យា



លោកគ្រូ មួន រីម
មុខវិជ្ជា ៖ ភូមិវិទ្យា & ប្រវត្តិវិទ្យា



អ្នកគ្រូ សម សុឡាវី
មុខវិជ្ជា ៖សីលធម៌-ពលរដ្ឋ



លោកគ្រូ ហេង ឈុនសិញ
មុខវិជ្ជា ៖ សេដ្ឋកិច្ចវិទ្យា



អ្នកគ្រូ ពិន គិមហុង
មុខវិជ្ជា ៖ ជីវវិទ្យា & ផែនដីវិទ្យា

# ការបង្រៀន និងរៀនផ្នែកខេមរភាសា

## ១. ម៉ោងសិក្សាៈ

ចាប់ពីម៉ោង៨:០០ ដល់ម៉ោង១៧:០០ (ថ្ងៃចន្ទ ដល់សុក្រ) និងព្រឹកថ្ងៃសៅរ៍ ។

## ២. កម្មវិធីសិក្សា

- **ភាសាខ្មែរ** ៖ រៀនអាន សរសេរ រៀនពាក្យ មេសូត្រ កំណាព្យ សរសេរតាមអាន វេយ្យាករណ៍ តែងសេចក្ដី
- **គណិតវិទ្យា** ៖ នព្វន្ត ពិជគណិត និងធរណីមាត្រ
- **វិទ្យាសាស្ត្រ** ៖ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី និងបរិស្ថានវិទ្យា
- **វិទ្យាសាស្ត្រសង្គម** ៖ ភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា គំនូរ គេហវិទ្យា និងសិល្បៈ
- **អប់រំកាយ កីឡា** ៖ កាយសម្ព័ន្ធ អត្តពលកម្ម និងកីឡារួម(បាល់បោះ បាល់ទះ បាល់ទាត់...)
- **សិល្បៈ** ៖ តន្ត្រី ចម្រៀង របាំ
- **ចំនួនម៉ោងសិក្សា** ៖ ផ្អែកតាមម៉ោងសិក្សានីមួយៗនៃមេរៀនក្នុងសៀវភៅគោលរបស់ក្រសួងអប់រំ ដោយតម្រូវឱ្យសិស្សរៀនបានគ្រប់មេរៀនដែលមានក្នុងសៀវភៅសិក្សាគោល និងការស្រាវជ្រាវរបស់គ្រូ។

## ៣. វិធីសាស្ត្រក្នុងការបង្រៀន

ផ្អែកលើគោលវិធីសិស្សមជ្ឈមណ្ឌល និង IBL (Iquiry Based Learning)
គ្រូជាអ្នកណែនាំមេរៀន សិស្សជាអ្នកស្វែងយល់ពីមេរៀនតាមរយៈការស្រាវជ្រាវបង្កើតជាសំណួរ ស្វែងរកចម្លើយ និងអំណះអំណាងដើម្បីទាញរកការសន្និដ្ឋាន គ្រូជាអ្នកលើកទឹកចិត្តការងារបុគ្គល និងការងារក្រុម ដើម្បីធ្វើការពិភាក្សាធ្វើបទបង្ហាញចែករំលែកចំណេះដឹង។












**ទ្រឹស្ដីផ្សាភ្ជាប់ជាមួយនឹងការអនុវត្តន៍ ឬការពិសោធន៍**

កិច្ចការផ្ទះ កិច្ចការស្រាវជ្រាវ៖ កិច្ចការផ្ទះ ឬកិច្ចការស្រាវជ្រាវ ត្រូវបានតាក់តែងដាក់ឱ្យសិស្សធ្វើជាប្រចាំតាមមេរៀនដែលបានរៀន ដែលតម្រូវឱ្យសិស្សសរសេរចូលក្នុងសៀវភៅកិច្ចការផ្ទះ និងសៀវភៅកំណត់ត្រាប្រចាំថ្ងៃដោយមានចុះហត្ថលេខា ពីសំណាក់មាតា បិតា អ្នកអាណាព្យាបាល និងគ្រូមុខវិជ្ជានីមួយៗ។ ការដាក់កិច្ចការផ្ទះ និងការអានមេរៀនពីថ្នាក់ទី១ដល់ទី១២ ភាគច្រើន មានរយៈពេលត្រឹមពី៥នាទី ដល់២០នាទីយ៉ាងច្រើន សម្រាប់សិស្សធ្វើដោយយកចិត្តទុកដាក់ដែលបានមកពីលោកគ្រូ អ្នកគ្រូ។ ការដាក់កិច្ចការផ្ទះ គឺជាកត្តាជំរុញឱ្យកូនៗចេះស្វ័យសិក្សាស្រាវជ្រាវ ឬដើម្បីឱ្យមានការចូលរួមពីសំណាក់គ្រួសារ។

## ៤. ការវាយតម្លៃលទ្ធផលការសិក្សាសិស្ស

សិស្សអាចឡើងថ្នាក់បានលុះត្រាតែក្នុងករណីជាប់មធ្យមភាគប្រចាំឆ្នាំលើការសិក្សា មិនមានចំនួនអវត្តមានច្រើន ដូចបានកំណត់ និងមានសីលធម៌រស់នៅល្អ ។



សិស្សឆ្នើម និងមានស្នាដៃល្អប្រចាំខែ និងឆមាស



សិស្សចូលរួមស្តាប់ការណែនាំ អប់រំវិន័យ និងសីលធម៌រស់នៅ








- **ការប្រឡងវាស់ស្ទង់សមត្ថភាពសិក្សារបស់សិស្ស**

ឆ្នាំសិក្សាបែងចែកជាពីរឆមាសក្នុងនោះឆមាសទី១ចាប់ពីខែសីហា រហូតដល់ខែធ្នូ និងឆមាសទី២ចាប់ពីខែមករា រហូតដល់ខែមិថុនា ការវាស់ស្ទង់សមត្ថភាពបែងចែកជាពីរគឺ ប្រឡងប្រចាំខែ និងប្រឡងប្រចាំឆមាសនីមួយៗ។

**-ប្រឡងប្រចាំខែ៖** ជារៀងរាល់ពាក់កណ្ដាលខែ ឬចុងខែនីមួយៗ សិស្សទាំងអស់ត្រូវធ្វើសំណួរវាស់ស្ទង់សមត្ថភាពនៅរាល់សប្ដាហ៍ទី៣ ឬទី៤ នៃខែនីមួយៗចំពោះមុខវិជ្ជាដែលបានសិក្សាកន្លងមក។

**-ប្រឡងឆមាស៖** រៀងរាល់បួនខែម្ដង សិស្សត្រូវប្រឡងវាយតម្លៃកម្រិតស្ដង់ដាឆមាសចំនួន២លើក នូវសមត្ថភាពដែលបានរៀនក្នុងកំឡុងពេលបួនខែ ឬមួយឆមាសម្ដង។

**-លទ្ធផលសិក្សាប្រចាំឆ្នាំ៖** គឺជាការយកពិន្ទុវាយតម្លៃសិក្សាប្រចាំខែ នៃឆមាសនីមួយៗបូកបញ្ចូលគ្នា រួចចែកនឹងបី(បីខែ) បានលទ្ធផលមធ្យមភាគប្រចាំខែក្នុងឆមាស។ បានលទ្ធផលមធ្យមភាគប្រចាំខែ យកមកបូកជាមួយមធ្យមភាគនៃការប្រឡងឆមាសរួចចែកនឹង២ ដើម្បីរកមធ្យមភាគប្រចាំឆមាសនីមួយៗ។ បន្ទាប់ពីបានមធ្យមភាគប្រចាំឆមាស (ឆមាសទី១ និងឆមាសទី២) បូកចូលគ្នា រួចចែកនឹង២ម្ដងទៀត ទើបទទួលបានមធ្យមភាគប្រចាំឆ្នាំសិក្សា ។

- **វត្តមាន និងអវត្តមានក្នុងម៉ោងការសិក្សា**

សិស្សទាំងអស់ត្រូវមករៀនឱ្យបានទៀងទាត់ បើករណីឈប់ត្រូវសុំច្បាប់ ដោយផ្ដល់ព័ត៌មានដល់ លោកគ្រូ-អ្នកគ្រូ ឬការិយាល័យរដ្ឋបាលរបស់សាលាដោយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលជាអ្នកសុំច្បាប់។

- ករណីឈប់ឥតច្បាប់៥ដង ឬឈប់មានច្បាប់១០ដង សាលានឹងចេញលិខិតរំលឹកលើកទី១ដោយនាយកប្រតិបត្តិ។
- ករណីបន្តឈប់ឥតច្បាប់ និងមានច្បាប់ចាប់ពី២០ដង សាលានឹងចេញលិខិតជូនដំណឹងជាលើកទី២ ហើយសិស្សនឹងត្រូវប្រឡងឡើងថ្នាក់ទោះជាមានមធ្យមភាគប្រឡងប្រចាំឆ្នាំជាប់ក៏ដោយ។
- ករណីអវត្តមានឥតច្បាប់ និងមានច្បាប់ចាប់ពី៣០ដងឡើងទៅសិស្សនឹងត្រូវរៀនត្រួតថ្នាក់។





សិស្សថ្នាក់ទី៦ ត្រូវបានបញ្ចប់កម្រិតថ្នាក់បឋមសិក្សា ឈានបន្តទៅកម្រិតសិក្សានៅថ្នាក់អនុវិទ្យាល័យ








- **ការផ្តល់ព័ត៌មានសិក្សា និងសកម្មភាពរបស់កូនៗ**

ផ្នែកខេមរភាសា មាននយោបាយផ្តល់ព័ត៌មានតាមរយៈជាសៀវភៅតាមដានការសិក្សាជាប្រចាំខែ ឬតាមរយៈ លិខិត និងតាមរយៈទូរស័ព្ទទៅកាន់មាតា បិតា ឬអ្នកអាណាព្យាបាលដោយផ្ទាល់ ។ លោក លោកស្រី អាចធ្វើការជួយតាមដានការសិក្សា កូនៗតាមរយៈកាលវិភាគ និងម៉ោងសិក្សាប្រចាំថ្ងៃ ទាំងរៀននៅសាលា និងរៀននៅផ្ទះ ដោយសួរនាំពីការធ្វើកិច្ចការផ្ទះ ការពិនិត្យសម្ភារៈសិក្សាក្នុងកាបូប និងលិខិតផ្តល់ព័ត៌មានផ្សេងៗពីខាងសាលាផ្ញើជូនលោកលោកស្រី ឬអ្នកអាណាព្យាបាល ។

រាល់ការទំនាក់ទំនងសម្រាប់ការសុំ ឬផ្តល់ព័ត៌មានបន្ថែមអំពីការសិក្សាកូនៗ ផ្នែករដ្ឋបាលនៃសាលាអន្តរជាតិ ISSR តែងតែផ្តល់ជូនជាប្រចាំ និងទទួលស្វាគមន៍ រាល់វត្តមានរបស់មាតា បិតា ឬអ្នកអាណាព្យាបាលជានិច្ច ។







## ៥. សិល្បៈ

ក្រៅពីការសិក្សាតាមសៀវភៅសិក្សាគោល សិស្សានុសិស្សក៏មានជម្រើសក្នុងការរៀនបន្ថែមលើមុខវិជ្ជាសិល្បៈរបាំបុរាណ និងរបាំប្រពៃណីខ្មែរ (តន្ត្រី និងរបាំ) ដើម្បីបណ្តុះគំនិតស្រឡាញ់វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីជាតិ មានបំណិនទំនាក់ទំនងល្អក្នុងសង្គម និងធ្វើឱ្យមានសុខភាពផ្លូវចិត្តកាន់តែរឹងមាំ និងស្រស់ស្រាយថែមមួយកម្រិតទៀត។










## ៦. កីឡា

សិស្សទាំងអស់នឹងទទួលបានការបណ្ដុះបណ្ដាលលើមុខវិជ្ជាអប់រំកាយ និងកីឡារួម ដើម្បីលើកកម្ពស់សុខភាពផ្លូវកាយ ចិត្តស្មារតី និងមានសាមគ្គីភាពជាក្រុមឱ្យបានកាន់តែប្រសើរ ដើម្បីសម្របខ្លួនបានគ្រប់កាលៈទេសៈ។







ការហ្វឹកហាត់កីឡាករបាល់ទាត់ បាល់បោះកុមារាអាយុក្រោម១២ឆ្នាំ និងការទទួលបានជ័យលាភីលេខ២ ពីការចូលរួមប្រកួតជម្រើសថ្នាក់ខេត្ត ឆ្នាំ២០២៣








## ការចូលរួមគាំទ្រ ពីអាណាព្យាបាល សហគមន៍ និងដៃគូ

- ជាការពិតណាស់ការសិក្សារបស់សិស្សានុសិស្ស ចាំបាច់ត្រូវតែមានការចូលរួមយ៉ាងសកម្មពីសំណាក់ឪពុក ម្ដាយ និងអ្នកអាណាព្យាបាលដើម្បីចូលរួមអភិវឌ្ឍនូវចំណេះដឹងនិងសម្បទារបស់កូនៗឱ្យកាន់តែមានភាពប្រសើរឡើង។ ការចូលរួមពីឪពុក ម្ដាយ និងអ្នកអាណាព្យាបាលមានដូចជា៖ ការតាមដានការរស់នៅ ការហូបចុក ការគេង ការសិក្សានៅផ្ទះបន្ថែម ការធ្វើកិច្ចការផ្ទះ ការអានសៀវភៅ ឬឯកសារផ្សេងៗ និងការផ្ដល់ព័ត៌មានត្រលប់មកសាលាវិញ និងចូលរួមប្រជុំចាំបាច់របស់សាលា ព្រមទាំងការជួយណែនាំកូនៗឱ្យយល់ដឹងពីបញ្ហាសង្គមទូទៅមួយចំនួនដែលពួកគេកំពុងរស់នៅ។
- សាលាតែងតែមានកម្មវិធីជួបប្រជុំជាមួយមាតា បិតា អាណាព្យាបាលសិស្ស ស្ដីអំពីការសិក្សារបស់សិស្សចំនួនបីដង ឬលើសពីនេះតាមស្ថានភាពជាក់ស្ដែងនៃសិស្សក្នុងមួយឆ្នាំសិក្សា ដើម្បីផ្ដល់ព័ត៌មានទាក់ទងនឹងការវិវត្តន៍នៃការងាររៀនសូត្ររបស់សិស្ស និងបានចែករំលែកនូវព័ត៌មានចាំបាច់មួយចំនួន ដើម្បីជួយកូនៗឱ្យរៀនសូត្របានទាន់ពេលវេលា និងកាន់តែល្អប្រសើរបានមួយកម្រិតថែមទៀត។





ការជួបប្រជុំរវាងមាតាបិតាសិស្ស និងអ្នកគ្រូប្រចាំថ្នាក់





## ការលើកទឹកចិត្ត

សិសស្សដែលរៀនបានចំណាត់ពីលេខ១ដល់លេខ៣ និងសិស្សពូកែតាមមុខវិជ្ជា មានអាទិភាពនឹងទទួលបានប័ណ្ណសរសើរ និងសក្ខីប័ណ្ណលើកទឹកចិត្ត ពីអ្នកគ្រូប្រចាំថ្នាក់ និងនាយកកម្មវិធីខេមរភាសា។










## សុខភាព សុវត្ថិភាព និងសន្តិសុខ

- បញ្ហាសុខភាព គឺជាចំណុចដ៏សំខាន់មួយ ដែលសាលា និងមាតា បិតា អ្នកអាណាព្យាលចូលរួមយកចិត្តទុកដាក់ទាំងអស់គ្នាសម្រាប់សុខភាពកូនៗ និងសុខភាពសិក្សា ជាពិសេសពេលកូនៗនៅផ្ទះ សូមមាតា បិតា ចូលរួមតាមដាន និងជំរុញ កូនៗជាប្រចាំ ឱ្យពួកគេឆាប់ចូលគេងបន្ទាប់ពីមើលមេរៀន ឬធ្វើកិច្ចការផ្ទះដែលសាលាបានដាក់ឱ្យរួចរាល់ ។ តាមដានថាតើកូនៗបានគេងហើយឬនៅ ឬក៏នៅបន្តលេង ឬធ្វើអ្វីផ្សេងៗទៀតរហូតដល់យប់ជ្រៅ ដែលជាហេតុអាចនាំឱ្យសិស្សមានអាការងងុយគេង និងស្វាបច្រើន ឈឺក្បាលវិលមុខ ថែមទាំងមិនអាចផ្តង់ស្មារតីរៀនបានល្អ និងមិនចង់ចូលរួមពិភាក្សាការងារជាក្រុមជាមួយមិត្តភក្តិដទៃទៀតនៅក្នុងថ្នាក់រៀនជាដើម ។
- ចំពោះម្ហូបអាហារ សាលាក៏ដូចជាលោកគ្រូ អ្នកគ្រូតែងតែជំរុញឱ្យសិស្សានុសិស្ស ញ៉ាំអាហារណាដែលមានជីវជាតិគ្រប់គ្រាន់ជួយទ្រទ្រង់ដល់សុខភាពរាងកាយ និងខួរក្បាល ជាពិសេសជាតិបន្លែ ត្រី សាច់ និងផ្លែឈើតាមរដូវកាលដែលមិនមានផលប៉ះពាល់ដល់សុខភាពកូនៗ ។
- ចំពោះសុវត្ថិភាព និងសន្តិសុខក្នុងការជូនកូនៗមកសាលា និងជូនត្រឡប់ទៅផ្ទះវិញ សូមលោក លោកស្រីផ្តល់ព័ត៌មានមកសាលាឱ្យបានច្បាស់លាស់ ក្នុងករណីដែលលោក លោកស្រីអនុញ្ញាតឱ្យបុគ្គលណាម្នាក់ជាអ្នកមកទទួលកូនៗ និងត្រូវចូលរួមសហការជាមួយនឹងបុគ្គលិកសន្តិសុខ ឬជំនួយការគ្រូ និងចុះហត្ថលេខាទទួលយកកូនៗនៅកន្លែងរង់ចាំ។ សាលាមិនអនុញ្ញាតជូនលោក លោកស្រី ចូលដើរមើលតាមបន្ទប់រៀនរបស់កូនៗ ឬនាំកូនតូចៗឱ្យចេញចូលរត់លេងខាងក្នុងបរិវេណសាលា ឬទីធ្លាលេងកម្សាន្តផ្សេងៗពេលដែលកំពុងរង់ចាំទទួលកូនៗបានឡើយ លើកលែងករណីមានការអនុញ្ញាតពីខាងសាលា ។

យើងខ្ញុំសូមអធ្យាស្រ័យពីសំណាក់ លោក លោកស្រី មាតាបិតា អ្នកអាណាព្យាបាលសិស្សទាំងអស់ មេត្តាយោគយល់ និងចូលរួមអនុវត្តតាមលក្ខខណ្ឌ សញ្ញាការណែនាំ ឬបម្រាមរបស់សាលាឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## សម្លៀកបំពាក់ និងឯកសណ្ឋានសិស្សានុសិស្ស

**សិស្សានុសិស្សផ្នែកខេមរភាសា តម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានតាមការកំណត់របស់សាលា៖**

- សិស្សកម្រិតថ្នាក់មត្តេយ្យ និងបឋមសិក្សា គឺតម្រូវឱ្យស្លៀកខោ ឬសំពត់ឱ្យបានសមរម្យ និងពាក់អាវតាមឯកសណ្ឋានរបស់សាលានៃពណ៌អាវតាមកម្រិតថ្នាក់នីមួយៗ និងរៀបចំខ្លួនប្រាណ សក់ក្បាលបានស្អាតសមរម្យ។
- សិស្សកម្រិតថ្នាក់មធ្យមសិក្សា៖ ត្រូវស្លៀកខោ ដែលមានសាច់ក្រណាត់លាត ពណ៌ខៀវទឹកប៊ិច ឬពណ៌ខៀវក្រម៉ៅ និងដាក់អាវចូលក្នុងខោ ឬសំពត់ជានិច្ច(ចៀសវាងប្រភេទសាច់ក្រណាត់រឹបរាង និងខោខូវប៊ូយ)។
- សិស្សប្រុសមានសក់ក្បាលត្រូវខ្លីជានិច្ច។ សិស្សស្រី ត្រូវចងសក់ និងរៀបចំឱ្យបានសមរម្យក្នុងបរិវេណសាលា។











# សកម្មភាពពិសេស និងសកម្មភាពក្រៅថ្នាក់សិក្សា



សកម្មភាពពិសេសជាសហកម្មវិធីសិក្សាសម្រាប់បំពេញបន្ថែមការបង្រៀននិងរៀនក្នុងថ្នាក់។ សកម្មភាពនេះមានជារៀងរាល់សប្តាហ៍ ដោយរៀបចំធ្វើអំឡុងពេលមុនម៉ោងសិក្សា ញាំបាយថ្ងៃត្រង់ ឬពេលទំនេរណាមួយ ដើម្បីផ្តល់ឱកាសឱ្យសិស្សពង្រឹងភាពម្ចាស់ការ អនុវត្តចំណេះដឹងបំណិនដែលខ្លួនទទួលបានពីថ្នាក់រៀន ហើយក៏ផ្តល់ឱកាសឱ្យសិស្សបានបញ្ចេញទេពកោសល្យតាមឧបនិស្ស័យដែលខ្លួនមានពីកំណើតផងដែរ ។



### ក. ការបែងចែកសកម្មភាព៖

១. សកម្មភាពបែងចែកសិស្សតាមថ្នាក់នីមួយៗ។
២. សកម្មភាពតាមក្លឹប (club) សិក្សា។
៣. សកម្មភាពតាមទស្សនកិច្ចសិក្សា។
៤. សកម្មភាពតាមក្រុមឯកសណ្ឋានដែលបានបែងចែក។
៥. សកម្មភាពបំណិនជីវិត កីឡា និងសិល្បៈ។

- សាលាតែងតែបានរៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធការសិក្សារបស់សិស្សជាមួយនឹងសាលាអន្តរជាតិជាដៃគូក្នុងរយៈពេលខ្លី។
- រៀបចំដំណើរទស្សនកិច្ចសិក្សាផ្សាភ្ជាប់នឹងមេរៀនដែលបានរៀន ឬកំពុងរៀន។
- កម្មវិធីការប្រកួតកីឡា សម្តែងសិល្បៈ ប្រគុំតន្ត្រី តាំងពិព័រណ៍ ដើម្បីប្រមូលមូលនិធិឧបត្ថម្ភទៅមន្ទីរពេទ្យកុមារ និងបានអំពាវនាវចំពោះសប្បុរសជនជាថវិកា និងសម្ភារដើម្បីជួយដល់កុមារកំព្រា។
- សម្អាតបរិស្ថានតាមដងផ្លូវក្នុងសហគមន៍ជាដើម និងចូលរួមទិវាផ្សេងៗរបស់សង្គមនៅក្នុងឆ្នាំសិក្សានីមួយៗ ។

សកម្មភាពទាំងនេះអាចប្រព្រឹត្តទៅបាន ដោយមានការឯកភាពពីមាតាបិតា អ្នកអាណាព្យាបាល ឬចាត់តាំងពីគ្រូបន្ទុកថ្នាក់ និងនាយកសាលា។












**ខ. មុខងារ នៃសកម្មភាពពិសេស៖**

១. ពង្រឹងចំណេះដឹង បំណិន ចរិយា គឺជាគុណតម្លៃ ដែលទទួលបានមកពីការសិក្សាអប់រំ ។

២. រឹតចំណងមិត្តភាពរវាងសិស្ស និងសិស្ស សាលារៀន និងសាលារៀន និងរវាងសាលារៀននិងសហគមន៍ ។

៣. ទស្សនកិច្ចសិក្សា និងកម្សាន្ត ដើម្បីសិក្សាស្វែងយល់បន្ថែមនូវអ្វីថ្មីៗ និងកាត់បន្ថយភាពតានតឹង រីករាយក្នុងការសិក្សាស្រាវជ្រាវ។

៤. ពង្រឹងសណ្ដាប់ធ្នាប់ល្អ វិន័យសេចក្ដីក្លាហានមានទំនុកចិត្តលើខ្លួនឯង ។

# សកម្មភាពមនុស្សធម៌ក្នុងសង្គម






# វប្បធម៌របស់សាលាអន្តរជាតិ ISSR

វប្បធម៌សាលារៀនអន្តរជាតិ ISSR សំដៅទៅលើបរិស្ថានទាំងមូលនៃសាលារៀន វប្បធម៌សាលារៀនមានទិដ្ឋភាពសង្គមទិដ្ឋភាពរូប ទិដ្ឋភាពសិក្សារៀនសូត្រ និងការប្រើប្រាស់ភាសា។ ការយកចិត្តទុកដាក់លើបរិស្ថាននេះបានផ្ដល់ផលល្អដល់ការបង្រៀន និងរៀន។ ទន្ទឹមនឹងនេះការអប់រំវិន័យ ឥរិយាបថល្អ ស្មារតីទទួលខុសត្រូវរបស់សិស្សក៏ជាចំណុចយកចិត្តទុកដាក់ជាប្រចាំផងដែរ ៖



- **ទិដ្ឋភាពសង្គមនៃសាលារៀន**

- ការគោរពគ្នា សំពះគ្នាជាវប្បធម៌ខ្មែរ
- ទំនួលខុសត្រូវ
- សហប្រតិបត្តិការ
- គំនិតសមូហភាពអភិវឌ្ឍ
- មិត្តភាព ការសប្បាយរីករាយ
- យុត្តិធម៌ -ល-។



- **ទិដ្ឋភាពរូបនៃសាលារៀន**

- ភាពស្អាត
- សុវត្ថិភាព
- សម្ភារប្រើប្រាស់ល្អគ្រប់គ្រាន់
- ផាសុកភាព
- រចនាលម្អ - ល- ។

- **ទិដ្ឋភាពសិក្សារៀនសូត្រ**

- ជំរុញការសិក្សារៀនសូត្រ ដោយបង្កលក្ខណៈឱ្យសិស្សចូលចិត្តការសិក្សា ខិតខំធ្វើកិច្ចការ យកចិត្តទុកដាក់អាន ចូលចិត្តបញ្ចេញគំនិត យោបល់ ចូលរួមក្នុងសកម្មភាពពិភាក្សា សកម្មភាពបង្កើតស្នាដៃ សំណេរ សកម្មភាពសម្ដែងតួអង្គ..
- ជំរុញការសិក្សា ដោយផ្ដល់សៀវភៅសិក្សា ផែនទី រូបភាព និងរៀបចំបន្ទប់ពិសោធន៍ បណ្ណាល័យ ... ។ល។

- **ការប្រើប្រាស់ភាសា**

- ភាសាខ្មែរ និងអង់គ្លេស (សិស្សអាចប្រើប្រាស់បានត្រឹមត្រូវ មានភាពថ្លៃថ្នូរទាំងក្នុង និងក្រៅសាលារៀន) ។
- ភាសាបរទេស៖ ភាសាបារាំង ឬភាសាចិន (សិស្សអាចប្រើប្រាស់បាន ក្នុងស្ថានភាពសមស្រប) ។

# អនុសាសន៍

- **អនុសាសន៍ និងការសំណូមពរពី នាយកប្រតិបត្តិខេមរភាសា ចំពោះមាតាបិតា ព្រមទាំងសិស្សានុសិស្ស**

ក្នុងនាមខ្ញុំបាទនាយកប្រតិបត្តិ សូមធ្វើការចូលរួមយោបល់ជាមួយនឹងលោក លោកស្រីជាមាតាបិតាមេត្តាលើកកម្ពស់ ដោយយកចិត្តទុកដាក់អំពីសុខភាព និងបរិស្ថានសិក្សារបស់កូនៗ តាមរយៈការសួរនាំតាមដាន ពិនិត្យ និងជំរុញលើការសិក្សារៀនសូត្រ អានសៀវភៅ ឬមេរៀន ធ្វើកិច្ចការផ្ទះ ការស្រាវជ្រាវអំពីខ្លឹមសារ ដែលមានសារប្រយោជន៍ទ្រទ្រង់ដល់ការសិក្សា និងជាចំណេះដឹងទូទៅ សម្រាប់ពង្រីក និងពង្រឹងស្មារតី ពុទ្ធិយល់ដឹងផ្សេងៗដល់កូនៗឱ្យកាន់តែទូលំទូលាយ និងមានការរីវឌ្ឍន៍ទៅមុខជានិច្ច ។ ជាងនេះទៅទៀត សូមមាតាបិតា ចូលរួមសហការជាមួយនឹង លោកគ្រូ អ្នកគ្រូ ក្នុងការអប់រំដល់កូនៗនូវឥរិយាបថល្អ អាកប្បកិរិយាល្អ សីលធម៌ និងសុជីវធម៌រស់នៅល្អ ទាំងនៅផ្ទះ និងនៅទីសាធារណៈ ព្រមទាំងមានស្មារតីទទួលខុសត្រូវខ្ពស់។

ម៉្យាងវិញទៀត សូមលោក លោកស្រី មេត្តាចូលរួមជួយទប់ស្កាត់ ឬកាត់បន្ថយចំពោះកូនៗមួយចំនួនដែលចំណាយពេលវេលាច្រើនមិនសូវមានការគាំទ្រដល់ការរៀនសូត្ររបស់ពួកគេ ដូចជាការលេងហ្គេម មើលភាពយន្ត លេងតាមបណ្តាញសង្គម និងការប្រើប្រាស់គ្រឿងអេឡិកត្រូនិកច្រើន រហូតដល់យប់ជ្រៅ ដែលជាហេតុធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពនៃការសិក្សា ដូចជាការមករៀនយឺត ងងុយគេងក្នុងម៉ោងរៀន ធ្វើឱ្យកូនៗពុំមានចិត្តចង់រៀន និងចង់ស្តាប់គ្រូពន្យល់ នឹងបណ្តាលធ្វើឱ្យពួកគេមានការសិក្សាធ្លាក់ចុះ មិនសូវចងចាំបាត់បង់ការយកចិត្តទុកដាក់រៀនសូត្រ ឈានដល់ការធ្វើឱ្យបាត់ទំនុកចិត្តលើខ្លួនឯង និងខ្មាសអៀនចំពោះមិត្តរួមថ្នាក់ ឬគេចវេះមិនចង់មករៀន។

ដូចនេះក្នុងនាមខ្ញុំជានាយកប្រតិបត្តិ និងជំនួសមុខឱ្យគណៈគ្រប់គ្រងសាលា សូមសំណូមពរចំពោះមាតា បិតា អ្នកអាណាព្យាបាលសិស្សទាំងអស់ មេត្តាចូលរួមជួយបន្ថែមនូវកិច្ចការមួយចំនួនដូចខាងក្រោម ៖

**១.**តាមដានការសិក្សាកូនៗនៅគេហដ្ឋានដូចជាការធ្វើកិច្ចការផ្ទះ រួចជូនឪពុកម្តាយ អ្នកអាណាព្យាបាលពិនិត្យ និងចុះហត្ថលេខា ព្រមទាំងជំរុញឱ្យឆាប់ចូលដំណេកបានទៀងទាត់ ។

**២.**មានការកំណត់ពេលវេលា ឬបង្កើតវិន័យក្នុងការអនុញ្ញាតឱ្យប្រើប្រាស់នូវសម្ភារបច្ចេកវិទ្យា ដូចជា ទូរស័ព្ទ Tablet កុំព្យូទ័រ ការមើលទូរទស្សន៍ ការប្រើម៉ាស៊ីនហ្គេម...) ឱ្យបានល្អ និងសមស្របតាមការចាំបាច់ ។

**៣.**ជំរុញ និងទម្លាប់ឱ្យកូនៗពិនិត្យសម្ភារសិក្សាមុនពេលមកសាលារៀនជាប្រចាំ កុំឱ្យមានការភ្លេចសម្ភារសិក្សាផ្សេងៗ ដូចជា សៀវភៅសរសេរ សៀវភៅមេរៀន កិច្ចការផ្ទះ សៀវភៅរបាយការណ៍។ល។

**៤.** តាមដានបញ្ហាសុខភាព សុវត្ថិភាព ចំណីអាហារ និងអនាម័យផ្សេងៗជាប្រចាំពេលចេញពីផ្ទះ និងចេញពីសាលាទៅវិញ ។

**៥.** សូមផ្តល់ព័ត៌មានមកសាលាជាប្រចាំ នូវការសុំច្បាប់ ឬការឈប់សម្រាករបស់កូនៗ។

**៦.** សូមចូលរួមគោរព និងអនុវត្ត តាមបទបញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់សាលាដែលបានចែង។

**៧.** ការអញ្ជើញចូលរួមក្នុងកម្មវិធីសំខាន់ៗរបស់សាលា...។

# សន្និដ្ឋាន

ជារួមមក សិស្សានុសិស្សដែលបានមកសិក្សារៀនសូត្រនៅទីនេះ គឺនឹងទទួលបាននូវ ចំណេះដឹង ជំនាញ បំណិនឥរិយាបថល្អ និងការចេះរួមរស់នៅជាមួយគ្នា ចេះសហការគ្នា ព្រមទាំងមានតុល្យភាពរវាងប្រាជ្ញា ស្មារតីសញ្ចេតនា និងរូបកាយ។ កម្មវិធីសិក្សាគឺស្របទៅនឹងកម្មវិធីសិក្សាជាតិ និងកម្មវិធីអន្តរជាតិពិតប្រាកដ និងការច្នៃប្រឌិតថ្មីបន្ថែម។ សិស្សានុសិស្សនឹងទទួលបាននូវសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ដែលមានការទទួលស្គាល់ពីមន្ទីរ និងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯកម្មវិធីសិក្សាភាសាអង់គ្លេសនឹងទទួលបានពីស្ថាប័នCambridge នៃចក្រភពអង់គ្លេស នៅពេលសិស្សបានបញ្ចប់ការសិក្សាដោយជោគជ័យ ។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះលោក-លោកស្រី ជាមាតាបិតា អ្នកអាណាព្យាបាល ដែលតែងតែបានគាំទ្រ និងចូលរួមសហការបានយ៉ាងល្អជាមួយនឹងសាលាយើងខ្ញុំ ។

សូមគោរពជូនពរលោក-លោកស្រី ទទួលបាននូវសុខភាពល្អ សុភមង្គល វិបុលសុខក្នុងក្រុមគ្រួសារ និងទទួលបានជោគជ័យក្នុងអាជីពការងារ និងមុខរបរអាជីវកម្មគ្រប់ៗគ្នា ។ សូមអរគុណ.!

ពីសាលាអន្តរជាតិ ISSR

អុិនធើណេសិនណល ស្គូល អហ្វ សៀមរាប

International School of Siem Reap

## PRIMARY SCHOOL CAMPUS




## HIGH SCHOOL CAMPUS



## ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនង


https://issr.edu.kh/

012 878 782|098 878782

admin@issr.edu.kh

FIND US ON GOOGLE MAP

HIGH SCHOOL CAMPUS

PRIMARY SCHOOL CAMPUS